សាលាព្រះគម្ពីរភ្នំពេញ

លេខ៣ ខែតុលា ២០១៤

ព្រឹត្តិបត្រ វាលស្រែស្រូវទុំ

www.ppbs.edu.kh

ប្រសាសន៍របស់លោកមហាវិទ្យាធិការ ទេព សំណាង

# តាមរយៈការបន្ទាបខ្លួន យើងរៀន និងរីកចម្រើនលូតលាស់

នៅពេលប៉ុងស្រូបយកទឹកពេញ វាមិនអាចស្រូបទឹកថែមទៀតបានឡើយ។ ដូចគ្នា ពេលយើងថា ខ្លួនយើងចេះដឹងសព្វគ្រប់អស់ហើយ នោះយើងមិនអាចរៀនពីអ្នកដទៃនិងរីកចម្រើនលូតលាស់ទៅមុខទៀតបានឡើយ។ ហេតុអ្វីបានជាយើងថា ខ្លួនយើងចេះដឹងសព្វគ្រប់ហើយ? ជាញយដង យើងតែងឲ្យតម្លៃលើខ្លួនឯងខ្លាំងពេក។ យើងខ្លាចអ្នកដទៃមើលងាយយើង នៅពេលយើងទទួលស្គាល់ថា យើងត្រូវការរៀនពីពួកគេ។ ពាក្យថា "ខ្ញុំចេះសព្វគ្រប់ហើយ" អាចសម្លាប់យើងនៅក្នុងការរៀនសូត្រ និងការរីកចម្រើនលូតលាស់របស់យើងនៅក្នុងព្រះអម្ចាស់បាន។

នៅក្នុងសំបុត្ររបស់លោកប៉ុល សរសេរផ្ញើរជូនទៅពួកជំនុំកូរិនថូស លោកបង្ហាញពីការដែលសាសន៍យូដានិងសាសន៍ក្រេកនៅសម័យលោក មិនសុខចិត្តបន្ទាបខ្លួនរៀនពីព្រះជាម្ចាស់ទេ (ប្រៀបធៀប១កូរិនថូស១:១៨-២៥)។ ពួកគេបានឮពីព្រះគ្រីស្ទ តែពួកគេមានអំណួតយ៉ាងខ្លាំងអំពីចំណេះដឹង និងប្រាជ្ញារបស់ខ្លួនក្នុងការរៀន ឬឲ្យខ្លួនរីកចម្រើនលូតលាស់។ ក្នុងគំនិតសាសន៍យូដា ព្រះមេស្ស៊ីត្រូវតែយាងមកដោយទីសម្គាល់នៃការអស្ចារ្យ និង ព្រះហស្តដ៏ខ្លាំងពូកែ និងពោរពេញដោយសិរីរុងរឿងរបស់ព្រះ មិនមែនមកសុគតលើឈើឆ្កាងទេ រីឯសាសន៍ក្រេកគិតថា ការសុគតរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាង គឺជារឿងដ៏អាម៉ាស់បំផុត ជាភាពទន់ខ្សោយ និងល្ងង់ខ្លៅ មិនមែនជាទីសម្គាល់ពីប្រាជ្ញាឡើយ។ ប៉ុន្តែលោកប៉ុលរំឭកយើងថា សេចក្តីល្ងង់ខ្លៅរបស់ព្រះឈ្លាសវៃជាងមនុស្ស ហើយសេចក្តីកំសោយរបស់ព្រះខ្លាំងជាងមនុស្ស(១កូរិនថូស១:២៥)។ ប៉ុន្តែអ្នកដែលព្រមទទួលព្រះគ្រីស្ទ នឹងទទួលបានសេចក្តីសុចរិត សេចក្តីញែកជាបរិសុទ្ធ និងសេចក្តីប្រោសលោះ(ប្រៀបធៀប១កូរិនថូស១:៣០) សាសន៍យូដានិងសាសន៍ក្រិច ត្រូវការការបន្ទាបខ្លួនដូចគ្នា ដើម្បីរៀនឲ្យស្គាល់ព្រះគ្រីស្ទដែលត្រូវគេឆ្កាង ពួកគេត្រូវការសេចក្តីក្លាហានយ៉ាងខ្លាំងដើម្បីបន្ទាបខ្លួន ហើយនៅពេលពួកគេធ្វើបាន នោះគេនឹងអាចរៀន ហើយរីកចម្រើនលូតលាស់។ នេះជាផ្លូវរបស់ព្រះគ្រីស្ទ និងពួកអ្នកដែលដើរតាមទ្រង់។ ដោយការបន្ទាបអង្គទ្រង់ ព្រះគ្រីស្ទបានយកសណ្ឋានជាមនុស្ស ដើម្បីឲ្យទ្រង់អាចរៀន មានបទពិសោធន៍ និងក្លាយជាសម្តេចសង្ឃ ដែលស្មោះត្រង់ និងមានសេចក្តីមេត្តាករុណា ជួយសង្គ្រោះមនុស្ស (ហេព្រើរ ២:១៤-១៨)។ នៅក្នុងរបៀបដូចគ្នាដែរ លោកប៉ុលបានបន្ទាបខ្លួនគាត់ រៀននូវរបៀបផ្សេងៗនៃផ្នត់គំនិត និងគតិលោករបស់មនុស្ស ដើម្បីឲ្យគាត់អាចឈ្នះចិត្តពួកគេថ្វាយព្រះគ្រីស្ទបាន (១កូរិនថូស ៩:១៩-២៣)។

បើមនុស្សមកឯព្រះគ្រីស្ទ ហើយថា ខ្លួនគេដឹងទាំងអស់អំពីទ្រង់ នោះពួកគេមិនអាចរៀនពីទ្រង់ ឬស្គាល់ទ្រង់ពិតប្រាកដឡើយ ហើយជាលទ្ធផល ពួកគេនឹងបដិសេធទ្រង់ជាព្រះ និងព្រះសង្គ្រោះ។ ស្រដៀងគ្នាដែរ ប្រសិនបើយើងថា ខ្លួនយើងដឹងទាំងអស់អំពីព្រះគ្រីស្ទ នោះយើងនឹងមិនដែលរៀនពីការដើរតាមទ្រង់ ឬរីកចម្រើនលូតលាស់បានឡើយ។ ហេតុនេះ ទ្រង់បង្គាប់ឲ្យយើងបន្ទាបខ្លួន ចុះចូលនឹងទ្រង់ និងព្រះបន្ទូលរបស់ទ្រង់។ នៅពេលយើងអនុញ្ញាតឲ្យទ្រង់បង្រៀនយើងតាមរយៈព្រះបន្ទូលរបស់ទ្រង់ និងសូនថ្មៃយើងដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ នោះយើងនឹងរៀន ហើយលូតលាស់ សម្រាប់ជាសិរីល្អរបស់ទ្រង់។

យើងកំពុងធ្វើបែបនេះនៅសាលាព្រះគម្ពីរភ្នំពេញ។ យើងលើកទឹកចិត្តគ្នាទៅវិញទៅមក ទាំងនិស្សិត និងសាស្ត្រាចារ្យ ឲ្យក្លាយជាអ្នករៀនសូត្រដែលបន្ទាបខ្លួន។ នៅពេលយើងបន្ទាបខ្លួននៅចំពោះព្រះគ្រីស្ទ ព្រះបន្ទូលរបស់ទ្រង់ និងព្រះវិញ្ញាណរបស់ទ្រង់នៅក្នុងជីវិតរបស់យើងរាល់ថ្ងៃ នោះយើងរៀន និងរីកចម្រើនលូតលាស់ សម្រាប់ជាសិរីល្អដល់ទ្រង់។



# អ្វីដែលថ្មីនៅសាលាព្រះគម្ពីរភ្នំពេញ



**ហុង សំបូរ**

*ព្រះវិហារព្រះវិញ្ញាណបរិសុទ្ធ*

**ហេតុអ្វីបានជាអ្នកជ្រើសរើសមករៀននៅPPBS?** ខ្ញុំគិតថាPPBSជាសាលាព្រះគម្ពីរដ៏ប្រសើរមួយ ដែលអាចជួយឲ្យខ្ញុំលូតលាស់ និងបម្រើព្រះជាម្ចាស់ បានកាន់តែប្រសើរឡើង។

**តើអ្នកសង្ឃឹមនឹងធ្វើអ្វីបន្ទាប់ពីរៀនចប់?** ខ្ញុំចង់ធ្វើជាគ្រូគង្វាល ហើយខ្ញុំអាចជួយធ្វើជាអ្នកដឹកនាំចម្រៀង និងបង្រៀនក្រុមយុវជនផងដែរ។

**ចូរឲ្យគុណនាម៣ដែលពណ៌នាពីខ្លួនអ្នកផ្ទាល់:** អត់ធ្មត់ ស្លៀមស្ងាត់ ស្មោះត្រង់។



**លីម ស្រីនី**

*ព្រះវិហារព្រៃកថី*

**ហេតុអ្វីបានជាអ្នកជ្រើសរើសមករៀននៅPPBS?** PPBS ជាសាលាព្រះគម្ពីរល្បីឈ្មោះ មានគ្រូបរទេស និងខ្មែរ ដែលមានភាពចាស់ទុំ កោតខ្លាចព្រះជាម្ចាស់ និងមានបទពិសោធន៍។

**តើអ្នកសង្ឃឹមនឹងធ្វើអ្វីបន្ទាប់ពីរៀនចប់?** ខ្ញុំចង់បម្រើព្រះនៅក្នុងអង្គការគ្រីស្ទាន ខ្ញុំចង់បង្រៀនអង់គ្លេស ព្រះបន្ទូល របាំគ្រីស្ទាន ហ្គីតា និងចែកចាយសេចក្តីស្រឡាញ់ដល់អ្នកដទៃ។

**មេរៀនជីវិតធំបំផុតដែលព្រះបានបង្រៀនដល់អ្នកកាលពីឆ្នាំមុនគឺជាអ្វី?** ឲ្យចេះកោតខ្លាចព្រះ ចេះតស៊ូ និងឈរឲ្យមាំមួន។



**ផាត់ ចាន់ធា**

*ព្រះវិហារលើវវីងហៀល*

**ហេតុអ្វីបានជាអ្នក ជ្រើសរើសមករៀននៅPPBS?** ខ្ញុំចង់ថ្វាយជីវិតខ្ញុំទៅព្រះជាម្ចាស់ ដើម្បីបម្រើទ្រង់ជាមួយនឹងអំណោយទាន ដែលទ្រង់បានប្រទានដល់ខ្ញុំ។

**តើអ្នកសង្ឃឹមនឹងធ្វើអ្វីបន្ទាប់ពីរៀនចប់?** ខ្ញុំចង់ធ្វើជាបេសកជន ក្រោយរៀនចប់ពីសាលាព្រះគម្ពីរនេះទៅ។

**មេរៀនជីវិតធំបំផុតដែលព្រះបានបង្រៀនដល់អ្នកកាលពីឆ្នាំមុនគឺជាអ្វី?** គឺការអត់ធ្មត់ និងការតស៊ូ



**ទួន ឌី**

*ព្រះវិហារស្មៀរណា*

**ហេតុអ្វីបានជាអ្នកជ្រើសរើសមករៀននៅPPBS?** ខ្ញុំចង់ស្គាល់ព្រះឲ្យកាន់តែច្បាស់ និងមានទំនាក់ទំនងល្អជាមួយទ្រង់ និងផ្សាយដំណឹងល្អដល់អ្នកដទៃឲ្យស្គាល់ព្រះអង្គសង្គ្រោះ។

**តើអ្នកសង្ឃឹមនឹងធ្វើអ្វីបន្ទាប់ពីរៀនចប់?** ខ្ញុំចង់ធ្វើជាគ្រូគង្វាល។

**តើព័ន្ធកិច្ចបម្រើព្រះដែលអ្នកពេញចិត្តបំផុតនឹងបម្រើក្នុងពួកជំនុំរបស់អ្នកគឺអ្វី?** អធិប្បាយនិងបង្រៀនព្រះបន្ទូល។

**មេរៀនជីវិតធំបំផុត ដែលព្រះបានបង្រៀនដល់អ្នកកាលពីឆ្នាំមុនគឺជាអ្វី?** ឲ្យជឿនិងស្តាប់បង្គាប់ព្រះតែមួយ។



**ឡោ ឌី**

*ព្រះវិហារពន្លឺជីវិតតាខ្មៅ*

**ហេតុអ្វីបានជាអ្នក ជ្រើសរើសមករៀននៅPPBS?** ព្រោះខ្ញុំចង់ចូលទៅជិតទ្រង់ រស់ក្នុងការបម្រើទ្រង់ ចង់បានសេចក្តីសង្គ្រោះ

**តើអ្នកសង្ឃឹមនឹងធ្វើអ្វីបន្ទាប់ពីរៀនចប់?** ខ្ញុំចង់ធ្វើជាអ្នកផ្សាយដំណឹងល្អ។ តែបើព្រះសព្វព្រះទ័យ នោះខ្ញុំនឹងធ្វើជាគ្រូគង្វាល។

**តើព័ន្ធកិច្ចបម្រើព្រះដែលអ្នកពេញចិត្តបំផុតនឹងបម្រើក្នុងពួកជំនុំរបស់អ្នកគឺអ្វី?** គឺការផ្សាយដំណឹងល្អ ហើយខ្ញុំចូលចិត្ត និទានរឿងឲ្យកុមារស្តាប់។

គ្រូបង្រៀនភាសាអង់គ្លេសថ្មី



**James Walsh**
**Cambridge, England**

**“ជាង២០ឆ្នាំមកហើយដែលអាស៊ីអាគ្នេយ៍ជាផ្ទះរបស់ខ្ញុំ ហើយជាការល្អដែលខ្ញុំបានត្រឡប់មកម្តងទៀត។ ខ្ញុំទទួលបាន ការស្វាគមន៍យ៉ាងកក់ក្តៅពីសហគមន៍ ក្នុងសាលាព្រះគម្ពីរភ្នំពេញ ហើយអាចរាប់ថាជាឯកសិទ្ធិយ៉ាងពិសេសក្នុងការបម្រើនៅទីនេះ ក្នុងនាមជាគ្រូភាសាអង់គ្លេសមួយរូប។ ខ្ញុំសម្លឹងឆ្ពោះទៅរកការរំពឹងដ៏ធំដែលឆ្នាំនេះនឹងនាំមកឲ្យ”**

# សកម្មភាពក្នុងសាលា


ថ្វាយបង្គំព្រះជាម្ចាស់


ថ្នាក់ឆ្នាំទី៣ បង្រៀនដោយសាស្ត្រាចារ្យ Gilbert Appleby


សាស្ត្រាចារ្យ ញ៉េប វណ្ណា
បង្រៀនមុខវិជ្ជាគោលការណ៍សិក្សាធិការគ្រីស្ទាន


កម្មវិធីអធិស្ឋានរបស់សាលា


និស្សិតថ្មី ឆ្នាំទី១ ឆ្នាំសិក្សា២០១៤


ការបរិភោគអាហារថ្ងៃត្រង់ជុំគ្នា
ក្នុងក្រុមតូចរបស់សាស្ត្រាចារ្យMark Wilson

«សូមឲ្យអស់អ្នកដែលស្វែងរកទ្រង់បានរីករាយ ហើយមានសេចក្ដីអំណរចំពោះទ្រង់ ហើយឲ្យពួកអ្នកដែលស្រឡាញ់សេចក្ដីសង្គ្រោះនៃទ្រង់បានពោលជានិច្ចថា សូមឲ្យព្រះបានលើកដំកើងឡើង»
-ទំនុកដំកើង៧០:៤

## សេចក្តីអធិស្ឋាន :

1. សូមអធិស្ឋានឲ្យនិស្សិតយើងទាំងអស់រៀនពីព្រះអម្ចាស់របស់យើងដោយពិតប្រាកដនិងដោយចិត្តបន្ទាបខ្លួន។
2. សូមអធិស្ឋានសម្រាប់និស្សិតថ្មីនិងការប្តេជ្ញាចិត្តរបស់ពួកគេចំពោះការសិក្សានិងការត្រាស់ហៅរបស់ព្រះជាម្ចាស់។
3. សូមអធិស្ឋានសម្រាប់សមាជិកសាស្ត្រាចារ្យពេញពេលបន្ថែមទៀតនៅសាលា។
4. សូមអធិស្ឋានសម្រាប់អ្នកបកប្រែថ្មី ឲ្យពួកគាត់មានសមត្ថភាពអាចបកប្រែយ៉ាងត្រឹមត្រូវ។
5. សូមអធិស្ឋានសម្រាប់គណកម្មការនាយក និងថ្នាក់ដឹកនាំរបស់សាលា ទទួលបានប្រាជ្ញាពីព្រះជាម្ចាស់ដើម្បីដឹកនាំសាលាព្រះគម្ពីរភ្នំពេញ។



## ប្រតិទិនឆ្នាំសិក្សា២០១៤-២០១៥ :

| | |
|---|---|
| ១៨-៣១ កក្កដា | ចុះឈ្មោះចូលរៀនរបស់និស្សិតចាស់ (រួមទាំងនិស្សិតពាក់កណ្តាលពេល) |
| ២៥ កក្កដា | ពិធីប្រគល់សញ្ញាបត្រលើកទី២០ |
| ៩-១១កញ្ញា | ការប្រឡង និងការសម្ភាសន៍និស្សិតថ្មី |
| ១៥ កញ្ញា | ការចុះឈ្មោះចូលរៀនរបស់និស្សិតថ្មី |
| ១៥-១៩ កញ្ញា | វគ្គបំប៉នឆ្នាំទី១ |
| ២៩-៣០ កញ្ញា | ទិវាបើកបវេសនកាល |

***ចាប់ផ្តើមឆមាសទី១ ១ តុលា ២០១៤ ដល់ ៣០ មករា ២០១៥***

| | |
|---|---|
| ១២-១៣ មករា | ការចុះឈ្មោះចូលរៀនរបស់និស្សិត ព.ព សម្រាប់ឆមាសទី២ |
| ២-៤ កុម្ភៈ | ការប្រឡងដំណាច់ឆមាសទី១ |
| ៦-១០ កុម្ភៈ | ដំណើរចុះធ្វើព័ន្ធកិច្ចកម្មសិក្សា |
| ១១-២០ កុម្ភៈ | ការសម្រាកក្រោយប្រឡងឆមាសទី១ |

***ចាប់ផ្តើមឆមាសទី២ ២៣ កុម្ភៈ ដល់ ២៦ មិថុនា ២០១៥***

| | |
|---|---|
| ២៤-២៥ កុម្ភៈ | ការវាយតម្លៃការសិក្សារបស់និស្សិត |
| ១៣ មីនា | ទិវាខួបកំណើតសាលាលើកទី២៣ |
| ១៩-២០ មីនា | ទិវាកីឡារបស់សាលាព្រះគម្ពីរភ្នំពេញ |
| ២៩មិថុនា-២កក្កដា | ការប្រឡងដំណាច់ឆមាសទី២ |
| ៧ កក្កដា | ការវាយតម្លៃការសិក្សានាដំណាច់ឆ្នាំសម្រាប់ឆ្នាំទី៤/បរិញ្ញាបត្ររង |
| ៨-១១ កក្កដា | សកម្មភាពតាមថ្នាក់ |
| ១៣-១៤ កក្កដា | វាយតម្លៃការសិក្សានាដំណាច់ឆ្នាំ(ឆ្នាំទី១-៣) |
| ១៧ កក្កដា | ពិធីអរព្រះគុណនាដំណាច់ឆ្នាំសិក្សា |
| ២៤ កក្កដា | ពិធីប្រគល់សញ្ញាបត្រលើកទី២១ |

### *យើងខ្ញុំសូមថ្លែងអំណរគុណចំពោះដង្វាយរបស់លោកអ្នក!*

នាម:____________________ អស័យដ្ឋាន ឬ អ៊ីមែល:____________________

លេខទូរស័ព្ទ:____________________ មកពីពួកជំនុំឬអង្គការ: ____________________

របៀបដែលលោកអ្នកអាចថ្វាយដង្វាយ:

$____________________ ឬ ថ្វាយដង្វាយរបស់លោកអ្នកដោយបញ្ចូលទៅក្នុងធនាគារកម្ពុជាសាធារណៈ គណនីលេខ # ០៩០ ០២ ១១ ០០ ១៥២១ ឬប្រគល់ជូនផ្ទាល់ដល់ផ្នែកហិរញ្ញវត្ថុរបស់សាលាព្រះគម្ពីរភ្នំពេញ។

សូមបញ្ជាក់ឲ្យបានច្បាស់ដង្វាយរបស់លោកអ្នកសម្រាប់:

- ការប្រើប្រាស់ទូទៅ ☐
- ឧបត្ថម្ភដល់និស្សិត ☐
- អភិវឌ្ឍអាគារសិក្សា ☐
- ឧបត្ថម្ភដល់បណ្ណាល័យ ☐
- ឧបត្ថម្ភដល់ការបំពាក់គ្រឿងបរិក្ខាសាលា ☐

#២៥៥ ផ្លូវ២៨គ្រូសារ ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ប្រអប់សំបុត្រ ១១៥៤ ទូរស័ព្ទលេខ ០១២ ៩៣៩ ៥០៤

អ៊ីមែល ppbs@ppbs.edu.kh វិបសាយ www.ppbs.edu.kh